

នំម៉ាណាប្រចាំថ្ងៃ សម្រាប់យុវជន

# ហេតុអ្វីការមើលរូបអាសអាភាសមានគ្រោះថ្នាក់យ៉ាងនេះ?



# សេចក្តីផ្តើម

តើហេតុអ្វីមនុស្សជាច្រើន ចូលចិត្តមើលរូបអាសអាភាស? គេបានមើលវា ហាក់ដូចជាមិនមានបញ្ហាអ្វីទេ មែនទេ? រូបអាសអាភាសបានក្លាយជា ផ្នែកមួយនៃការរស់នៅប្រចាំថ្ងៃ របស់ពួកគេ។ តាមពិត "រូបអាសអាភាស" គឺជាចំណីភ្នែក និងអារម្មណ៍ដ៏គ្រោះថ្នាក់។

ប៉ុន្តែ តើវាគ្រាន់តែជាបញ្ហាដែលកើតមានជាធម្មតាមែនឬ? ការមើលរូប ឬវីដេអូអាសអាភាស ពីដំបូង ធ្វើឲ្យមានចិត្តរំភើប។ តែមិនយូរប៉ុន្មាន វាក៏បានក្លាយជាទម្លាប់ ក្នុងការរស់នៅ។ វាក៏បានគ្រប់គ្រង និងទាមទាយើង ឲ្យផ្តោតចិត្តទៅលើវា ហើយយើងក៏មានអារម្មណ៍ថា យឺតពេលហើយ វាមិនព្រមដោះលែងយើងទេ។ វាមានផលប៉ះពាល់មកលើការឲ្យតម្លៃខ្លួនឯង ទំនាក់ទំនង សមត្ថភាពនៅក្នុងការបើកចំហរ ការរំពឹងចង់បានខាងផ្លូវភេទ ហើយក៏ប៉ះពាល់សុខភាពផ្លូវចិត្តផងដែរ។ វាមិនមែនជាអាថ៌កំបាំងដ៏អាក្រក់តូចមួយ តែវាមានគ្រោះថ្នាក់ និងនាំមកនូវការបង្ខូចបំផ្លាញ ដែលនាំឲ្យយើងមានការភ័យខ្លាច និងអាម៉ាស់។

ប៉ុន្តែ ព្រះគម្ពីរប៊ីបបានផ្តល់ឲ្យនូវក្តីសង្ឃឹម សេរីភាពពិតប្រាកដ រួចផុតពីចំណងរបស់វា។ ទោះអ្នកមានបទពិសោធន៍យ៉ាងណាជាមួយរូបអាសអាភាស ឬមានអារម្មណ៍ថា ជាប់អន្ទាក់វាខ្លាំងយ៉ាងណាក៏ដោយ ក៏វានៅតែមិនអាចធំ និងមានអំណាចលើសព្រះ ដែលស្រឡាញ់យើងនោះឡើយ។ ព្រះអង្គបានចាត់ព្រះរាជបុត្រាតែមួយរបស់ព្រះអង្គ ព្រះនាមយេស៊ូវ ឲ្យមកសង្គ្រោះយើង ឲ្យរួចផុតពីការញៀន ការជាប់ចំណង និងក្តីអាម៉ាស់គ្រប់យ៉ាង។ ហើយនេះមិនគ្រាន់តែជាការរំដោះ ឲ្យយើងមានសេរីភាព ក្នុងនគរស្ថានសួគ៌ នៅពេលអនាគតប៉ុណ្ណោះឡើយ។ តែយើងអាចពិសោធន៍នឹងការរំដោះនេះ ក្នុងពេលបច្ចុប្បន្ន។

សូមចំណាយពេលស្វែងយល់ ដោយខ្លួនឯង ដូចតទៅ ...



ចេសិន(Jason) ទើបតែមកពីសាលារៀន។ នៅផ្ទះ គាត់មានអារម្មណ៍រសាប់រសល់។ គាត់មានកិច្ចការដែលគ្រូដាក់ឲ្យធ្វើ តែគាត់គ្មានអារម្មណ៍ធ្វើវាទេ ទោះថ្ងៃប្រលងកំពុងតែរំកិលជិតមកដល់ក៏ដោយ។ គាត់មានអារម្មណ៍ជ្រួលច្របាល។ តើគាត់ត្រូវធ្វើដូចម្ដេច?

តាមពិត ចេសិនដឹងថា ខ្លួនគាត់ចង់ធ្វើអ្វី។ ប៉ុន្តែ គាត់ព្យាយាមរំងាប់ចិត្តខ្លួនឯង កុំឲ្យធ្វើវា។ គាត់ដឹងថា បន្ទាប់ពីគាត់បានធ្វើវាហើយ គាត់នឹងមានអារម្មណ៍ប្រកាន់ទោសខ្លួនឯង និងអាមាស់។ គាត់ក៏បានបើកមើលកំព្យូទ័ររបស់គាត់។ គាត់គិតក្នុងចិត្តថា "ខ្ញុំនឹងបើកវាមើលនៅពេលក្រោយ"។ គាត់ក៏បានរើសសៀវភៅមកអាន ប៉ុន្តែ គាត់មានអារម្មណ៍ធុញទ្រាន់។ ទីបំផុត គាត់ក៏បានងាកទៅរកកំព្យូទ័រគាត់ ហើយក៏បានបើកវាឡើង។ គាត់គ្រាន់តែចុចប៊ូតុងតែបន្តិច គាត់ក៏បានចូលមើលក្នុងវេបសាយ ដែលគាត់ចូលចិត្ត។ បេះដូងគាត់ ក៏បានចាប់ផ្ដើមលោតកាន់តែញាប់ ហើយគាត់ក៏មានការភ័យខ្លាចខ្លះៗដែរ។ បើសិនជាឪពុកម្ដាយរបស់គាត់ដើរចូលមក តើគាត់នឹងធ្វើដូចម្ដេច? គាត់ក៏មិនអើពើរចំពោះសំណួរនេះ ហើយភ្នែកគាត់ក៏បានស្វែងរករូបភាព ដែលគាត់ត្រេកត្រអាលចង់មើល។ ចេសិនកំពុងតែមើលរូបអាសអាភាស។

គាត់មានអារម្មណ៍ថា ភាពរំភើបរីករាយ បានរត់កាត់គំនិត និងរូបកាយរបស់គាត់ ពេលដែលគាត់បានឃើញរូបមនុស្សស្រីអាក្រាតកាយ។ គាត់ភ្លេចអារម្មណ៍ធុញទ្រាន់ហើយ។ គាត់ភ្លេចភាពឯកោ។ គាត់ភ្លេចថា ពេលនេះជាពេលអ្វី។ គាត់ភ្លេចការព្រួយបារម្ភ និងភាពតប់ប្រម៉ល់ទាំងអស់។

រឿងនេះបានចាប់ផ្ដើមកើតឡើង ពេលដែលមិត្តភក្ដិរបស់គាត់ម្នាក់ បានផ្ញើ link របស់វេបសាយមួយ មកគាត់ដើម្បីនាំគាត់ចូលទៅក្នុងពិភពនៃរូបអាសអាភាស។ នៅថ្ងៃ និងសប្ដាហ៍បន្ទាប់ គាត់ក៏បានបន្តចូលមើលក្នុងវេបសាយអាសអាភាសទាំងនោះ ពេលណាគាត់អាចនៅតែម្នាក់ឯង ជាមួយនឹងកំព្យូទ័រលែបថប់របស់គាត់។ មិនយូរប៉ុន្មាន គាត់ក៏បានញាណ នឹងចំណីអារម្មណ៍ដែលគេហាមមិនឲ្យក្មេងក្រោមអាយុមើល។ គាត់ចង់មើលហើយមើលទៀត។

ប៉ុន្តែ មានរឿងមួយ ចាប់ផ្ដើមកើតឡើងចំពោះចេសិន។ គាត់មានអារម្មណ៍ប្រកាន់ទោសខ្លួនឯង។ គាត់មានអារម្មណ៍ថា ខ្លួនគាត់ត្រូវបានកាត់ផ្ដាច់ចេញពីពិភពលោកពិត។ គាត់មានអារម្មណ៍ថា ខ្លួនឯងស្មោកគ្រោក និងជាប់អន្ទាក់។ គាត់មានអារម្មណ៍ថា ហាក់ដូចជាជាប់នៅក្នុងពិភពស្រមើលស្រមៃ។

## ហេតុអ្វីរូបអាសអាភាស មានចំណុចអាក្រក់ច្រើនយ៉ាងនេះ?

រូបអាសអាភាសលើកដំកើងទស្សនៈខុសឆ្គង និងមិនប្រាកដនិយម អំពីផ្លូវភេទ ដែលមិនអើពើរទាល់តែសោះចំពោះចំណងដ៏បរិសុទ្ធ និងការប្ដេជ្ញាចិត្ត ក្នុងអាពាហ៍ពិពាហ៍ ដែលជាព្រំដែននៃការរួមភេទ។ រូបអាសអាភាសក៏មិនអើពើរ ចំពោះគ្រោះថ្នាក់នៃការមានផ្ទៃពោះដែលគេមិនចង់បាន និងជំងឺឆ្លងតាមការរួមភេទ។



រូបអាសអាភាស គឺជាការកុហក់ថា មនុស្សអាចរួមភេទ ដោយមិនចាំបាច់មានទំនាក់ទំនង ដែលស្មោះត្រង់ ហើយកុហក់អ្នកថា អ្នកអាចធ្វើវា នៅពេលណា និងជាមួយនរណាក៏បាន ដោយមិនចាំបាច់គិត អំពីផលវិបាក។ រូបអាសអាភាសនាំឲ្យអ្នកមិនខ្វល់អំពីអ្នកដទៃ ហើយគិតតែយកការសប្បាយផ្ទាល់ខ្លួន ជាសំខាន់។

តាមពិត រូបអាសអាភាស ធ្វើឲ្យអ្នកគិតតែពីផ្គាប់ចិត្តខ្លួនឯង។ ការគិតបែបអាត្មានិយមនេះបានបំផ្លាញគ្រឹះនៃទំនាក់ទំនងគ្រប់យ៉ាង។ តើធ្វើដូចម្ដេចឲ្យយើងអាចគោរពមនុស្សដែលយើងជួប ដោយចាត់ទុកពួកគេថា ដូចរូបអង្គរបស់ព្រះ(លោកុប្បត្តិ ១:២៧) នៅពេលដែលរូបអាសអាភាសបាននាំឲ្យយើងគិតថា មនុស្សគឺជាវត្ថុសម្រាប់ការសប្បាយរបស់យើងនោះ?

បន្តិចម្ដងៗ អ្នកនឹងមានចំណាប់អារម្មណ៍ ចំពោះចំណុចទាក់ទាញខាងផ្លូវភេទរបស់អ្នកដទៃ ខ្លាំងជាងចំណុចផ្សេងទៀតរបស់ពួកគេ។ អ្នកថែមទាំងកាត់បន្ថយការសន្ទនាជាមួយមិត្តភក្តិកាន់តែខ្លី ដើម្បីឲ្យអ្នកអាចត្រឡប់មកសម្ងំមើលរឿងអាសអាភាសតែឯងទៀត។

វាធ្វើឲ្យយើងចុះខ្សោយសមត្ថភាព នៅក្នុងការទំនាក់ទំនង ដោយបើកចំហរ ជាពិសេស ជាមួយមិត្តប្រុស ឬមិត្តស្រីរបស់យើង។ រូបអាសអាភាសមិនដែលលើកទឹកចិត្តយើងឲ្យមានការប្ដូរផ្ដាច់ចំពោះដៃគូរបស់យើងទេ តែវាបានជំរុញយើងឲ្យស្វែងរកមនុស្សថ្មីទៀត ដើម្បីពិសោធន៍ និងបំពេញចំណង់ផ្លូវភេទ ដែលមិនចេះគ្រប់គ្រាន់។

រូបអាសអាភាសធ្វើឲ្យយើងគិតថា ការរួមភេទ គឺដើម្បីសម្រេចបំណងខ្លួនឯង។ អ្នកមើលរូបអាសអាភាសក៏មានការពិបាក នៅក្នុងការបង្កើតទំនាក់ទំនងដែលមានភាពនឹងនរ ព្រោះពួកគេមិនអាចទទួលអ្វីដែលរូបអាសអាភាសបានសន្យាពួកគេ។

ជាងនេះទៅទៀត បុរស និងស្ត្រីក្នុងឧស្សាហកម្មអាសអាភាស តាមធម្មតា បង្ហាញចេញនូវទឹកមុខញញឹម និងភាពភ្លៀវភ្លា ដែលគ្រាន់តែជាការគ្របបាំងការបំពាន ការឈឺចាប់ និងការធ្វើទុក្ខទោសគ្រប់ប្រភេទ។ ដូចនេះ បើយើងមើលរូប ឬរឿងអាសអាស គឺមានន័យថា យើងបានយល់ស្រប ចំពោះការបំពានដែលពួកគេបានទទួលរងដើម្បីជាការសប្បាយរបស់យើង។

សង្គម ទំនាក់ទំនង និងអ្នកប្រើប្រាស់រឿងអាសអាភាស នីមួយៗ សុទ្ធតែជាជនរងគ្រោះ នៃរូបអាសអាភាស។

## សេរីភាពពិតប្រាកដ

មានមតិមួយពោលថា "ព្រះគម្ពីរប៊ីបការពារអ្នក កុំឲ្យធ្វើអំពើបាប តែអំពើបាបរារាំងអ្នកមិនឲ្យអានព្រះគម្ពីរប៊ីប"។

អាចនិយាយបានម្យ៉ាងទៀតថា "ព្រះគម្ពីរប៊ីបនឹងការពារអ្នក មិនឲ្យមើលរឿងអាសអាភាស ពុំនោះទេ រឿងអាសអាភាស នឹងរារាំងអ្នកមិនឲ្យមើលព្រះគម្ពីរប៊ីប"។

*ឯចង្កៀងរបស់រូបកាយ គឺជាភ្នែក ដូច្នេះ បើភ្នែកអ្នកល្អ នោះរូបកាយអ្នកទាំងមូលនឹងបានភ្លឺ តែបើភ្នែកអ្នកអាក្រក់*



*វិញ នោះរូបកាយអ្នកទាំងមូល នឹងត្រូវងងឹតសូន្យ យ៉ាងនោះ បើពន្លឺដែលនៅក្នុងខ្លួនអ្នក ជាសេចក្តីងងឹតហើយ ចុះសេចក្តីងងឹតនោះនឹងបានជាខ្លាំងអម្បាលម៉ានទៅហ្ន៎។ ម៉ាថាយ ៦:២២-២៣*

និយាយរួម ព្រះគម្ពីរប៊ីប និងរឿងអាសអាភាស មិនអាចនៅជាមួយគ្នាបានឡើយ។ អ្នកមិនអាចមើលព្រះគម្ពីរផង និងរឿងអាសអាភាសផងបានឡើយ។ អ្នកត្រូវបំពេញចិត្តគំនិតរបស់អ្នក(និង "រូបកាយទាំងមូល") ដោយព្រះបន្ទូលព្រះ ពុំនោះទេ រូបអាសអាភាសនឹងចូលពេញក្នុងចិត្តគំនិត និងរូបកាយអ្នក ពេលណាអ្នកមើលវា។

ដើម្បីរំដោះខ្លួនយើងឲ្យរួច ពីការញៀនរូបអាសអាភាស យើងត្រូវការអំណាច ដែលខ្លាំងជាងយើង ដើម្បីជួយយើង។ ព្រះគម្ពីរបានប្រាប់យើង "ឲ្យចោលអស់ទាំងបន្ទុក និងអំពើបាប ដែលរុំយើងជុំវិញជាងាយម្ល៉េះនោះចេញ ហើយត្រូវរត់ក្នុងទីប្រណាំង ដែលនៅមុខយើង ដោយអំណត់ **ទាំងរំពឹងមើល**ដល់ព្រះយេស៊ូវដ៏ជាមេផ្តើម ហើយជាមេសំរេចសេចក្តីជំនឿរបស់យើង"(ហេព្រើរ ១២:១-២)។ តើយើងត្រូវរំពឹងមើលដល់ព្រះយេស៊ូវ ដោយរបៀបណា?

គឺដោយស្វែងយល់អំពីព្រះជន្ម ការបង្រៀន ការអស្ចារ្យ ការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ ដែលមានចែងក្នុងព្រះគម្ពីរប៊ីប។ ព្រះគម្ពីរប៊ីបបានប្រាប់យើង អំពីព្រះយេស៊ូវ ដែលព្រះទ្រង់បានចាត់ ឲ្យយាងចុះមក ដើម្បីរំដោះយើង ឲ្យរួចពីអំណាចនៃអំពើបាបគ្រប់យ៉ាង ដែលរាប់បញ្ចូលទាំងការញៀនទាំងឡាយ និងដើម្បីបង្ហាញសេចក្តីស្រឡាញ់ពិតប្រាកដ។ ព្រះយេស៊ូវអាចរំដោះយើងឲ្យរួចផុតពីការអ្វីក៏ដោយ ដែលនាំមកនូវក្តីអាម៉ាស់ក្នុងជីវិតយើង។ ព្រះអង្គនឹងដឹកនាំយើងចូលក្នុងជីវិតថ្មី ដែលមានការអត់ទោសបាប ក្តីស្រឡាញ់ពិត និងការបើកចំហរ ដោយប្រទានជីវិតពេញបរិបូរមកយើង(យ៉ូហាន ១០:១០)។

កាលណាយើងញៀននឹងរឿងអាសអាភាសហើយ នោះយើងពិបាកជំរុះវាយចេញពីជីវិតយើងណាស់។ វាមានអំណាចខ្លាំងពេក មានការល្បួងលោកខ្លាំងពេក ទាមទាមកលើយើងខ្លាំងពេក ។ ប៉ុន្តែ យើងអាចជំនួសវា ដោយការស្គាល់ព្រះ តាមរយៈព្រះគម្ពីរ ដែលជាជម្រើសល្អជាង។ សូមចាំថា "ព្រះគម្ពីរប៊ីបនឹងការពារអ្នក មិនឲ្យមើលរឿងអាសអាភាស ពុំនោះទេ រឿងអាសអាភាសនឹងរារាំងអ្នក មិនឲ្យមើលព្រះគម្ពីរប៊ីប"។ បើយើងងាកបែរទៅរកសេចក្តីស្រឡាញ់ និងព្រះបន្ទូលសន្យារបស់ព្រះ ហើយឲ្យព្រះបន្ទូលព្រះអង្គជ្រួតជ្រាបភ្នែក និងគំនិតយើង នោះយើងនឹងឃើញការផ្លាស់ប្តូរ។ ការផ្លាស់ប្តូរនេះ នឹងកើតមាន ដោយអំណាចរបស់ព្រះ ដែលសព្វព្រះទ័យនឹងរំដោះយើង ឲ្យរួចពីអ្វី ដែល "ងាយនឹងចងរឹតយើង"។

កូនសៀវភៅនេះពេញទៅដោយព្រះបន្ទូលព្រះ នៅក្នុងព្រះគម្ពីរ និងការបកស្រាយ ដែលនឹងជួយអ្នកឲ្យចាប់ផ្តើមទម្លាប់ថ្មីមួយនេះ។ ការរំដោះខ្លួនឲ្យរួចពីចំណងនៃរូបអាសអាភាស មិនអាចធ្វើទៅបានភ្លាមៗនោះទេ។ ប៉ុន្តែ បើយើងរំពឹងមើលព្រះយេស៊ូវ ជាជាងមើលរូបអាសអាភាស នោះព្រះអង្គនឹងរំដោះយើងឲ្យមានសេរីភាពមិនខាន (យ៉ូហាន ៨:៣៦)។



# អេភេសូរ ៥:៨-១៤

៨ ដ្បិតកាលពីដើមអ្នករាល់គ្នាក៏ងងឹតដែរ តែឥឡូវនេះវិញ បានភ្លឺក្នុងព្រះអម្ចាស់
ដូច្នេះ ចូរដើរដូចជាមនុស្សភ្លឺចុះ ៩ ដ្បិតផលផ្លែនៃពន្លឺ នោះមាននៅក្នុងគ្រប់ទាំង
កិរិយាល្អ សេចក្ដីសុចរិត និងសេចក្ដីពិត ១០ ចូរលមើលឲ្យដឹងសេចក្ដីអ្វី ដែល
ព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យចុះ ១១ កុំឲ្យប្រកបក្នុងការឥតផលប្រយោជន៍
របស់សេចក្ដីងងឹតឡើយ ស៊ូបន្ទោសវិញ ១២ ដ្បិតការទាំងប៉ុន្មានដែលគេប្រព្រឹត្ត
ដោយសំងាត់ នោះបើគ្រាន់តែនិយាយពីការទាំងនោះ ក៏គួរខ្មាសទៅហើយ ១៣
តែការទាំងនោះបានសំដែងមកយ៉ាងច្បាស់ ដោយពន្លឺភ្លឺបញ្ចាក់ ដ្បិតគឺជាពន្លឺ
ហើយ ដែលសំដែងឲ្យឃើញទាំងអស់ ១៤ ហេតុនោះបានជាទ្រង់មានព្រះបន្ទូល
ថា «ឯងដែលដេកលក់អើយ ចូរភ្ញាក់ឡើង ឲ្យក្រោកពីពួកមនុស្សស្លាប់ឡើង នោះ
ព្រះគ្រីស្ទនឹងភ្លឺមកលើឯង។

# ការរស់នៅ ដើម្បីផ្គាប់ចិត្តព្រះ

*ចូរដើរដូចជាមនុស្សភ្លឺចុះ ដ្បិតផលផ្លែនៃពន្លឺ នោះមាននៅក្នុងគ្រប់ទាំងកិរិយាល្អ សេចក្ដីសុចរិត និងសេចក្ដីពិត ចូរមើលឲ្យដឹងសេចក្ដីអ្វី ដែលព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យចុះ(អេភេសូរ ៥:៩-១០)។*

**ឧស្សាហកម្មអាសអាភាស** គឺជា "មុខជំនួញ" ដែលរកបានប្រាក់ចំណេញរាប់ពាន់លានដុល្លា ក្នុងមួយឆ្នាំ។ ប៉ុន្តែ វាបានបន្សល់ទុកនូវការញៀន ការឈឺចាប់ ការភ័ន្តភាំង និងការបាក់បែក ក្នុងគ្រួសារ។ ហេតុអ្វីក៏រូបអាសអាភាសអាក្រក់យ៉ាងនេះ សម្រាប់យើង? ព្រោះវាជាផ្ទុយស្រឡះនឹងផែនការដែលព្រះទ្រង់មានសម្រាប់ផ្លូវភេទ។ ការរួមភេទ គឺសម្រាប់តែប្ដីមួយ និងប្រពន្ធមួយ ក្នុងទំនាក់ទំនងប្ដីប្រពន្ធរបស់ពួកគេ។ វានាំទៅរកភាពជិតស្និទ្ធកាន់តែខ្លាំង ហើយនាំទៅរកការមានកូន ក្នុងករណីជាច្រើន។ រូបអាសអាភាស គឺដើម្បីតែខ្លួនឯង និងប្រយោជន៍ផ្ទាល់ខ្លួន វានាំឲ្យមានការឃ្លាតឆ្ងាយគ្នា ក្នុងទំនាក់ទំនងទាំងអស់របស់យើង ដោយរាប់បញ្ចូលទាំងទំនាក់ទំនងជាមួយព្រះផងដែរ។

វានាំឲ្យយើងគិតថា អ្នកដទៃគឺជាកម្មវត្ថុ នៃការសប្បាយរបស់យើង នាំឲ្យយើងមិនអាចមានភាពជិតស្និទ្ធ ជាមួយអ្នកដទៃ និងមានភាពបើកចំហរចំពោះពួកគេ។

មានគ្រីស្ទបរិស័ទម្នាក់ មានអារម្មណ៍ថា ខ្លួនបានជាប់អន្ទាក់នៃការញៀនរូបអាសអាភាស។ គាត់បានមករកខ្ញុំ ដើម្បីឲ្យខ្ញុំជួយគាត់ ហើយយើងក៏បានអានបទគម្ពីរ អេភេសូរ ៥:៨-២១ ជាមួយគ្នា។ បន្ទាប់មក យើងក៏បានជជែកគ្នា អំពី "សេចក្ដីល្អ សេចក្ដីសុចរិត និងសេចក្ដីពិត"(ខ.៩) ដែលបានមកពីការរស់នៅ ថ្វាយព្រះ ជាជាងរស់នៅ សម្រាប់ខ្លួនឯង។ ការរស់នៅនោះ គឺមានភាពល្អប្រសើរលើសលប់ ជាងជីវិតចន្លោះប្រហោង និងលាក់លៀម ដែលរូបអាសអាភាសបានរុញច្រានយើងឲ្យធ្លាក់ចូល។ ពេលណាយើងដឹងថា មានការអ្វីខ្លះដែល "ផ្គាប់ព្រះទ័យព្រះអម្ចាស់"(ខ.១០) យើងអាចរស់នៅ ក្នុងជីវិត ដែលពេញដោយព្រះវិញ្ញាណបរិសុទ្ធ និយាយគ្នាទៅវិញទៅមក ដោយបទទំនុកដំកើង ទំនុកបរិសុទ្ធ នឹងចំរៀងខាងឯវិញ្ញាណ ទាំងច្រៀង ហើយសរសើរដល់ព្រះអម្ចាស់ដោយអស់ពីចិត្ត(ខ.១៨-១៩)។ គ្មានអ្វីអាចប្រៀបផ្ទឹមនឹងក្ដីអំណរ សេរីភាព និងការស្កប់ចិត្ត និងជីវិត ដែលយកព្រះជាទីមួយ ហើយដើរតាមផ្លូវដ៏អស្ចារ្យរបស់ព្រះអង្គ។ មិនយូរប៉ុន្មាន មិត្តភក្តិរបស់ខ្ញុំម្នាក់នេះ ក៏បានលត់ជង្គង់ចុះលន់តួបាប ដោយថ្វាយការញៀនរបស់គាត់ដល់ព្រះ ហើយសូមឲ្យព្រះអង្គសម្អាតគាត់ឲ្យបរិសុទ្ធជាថ្មី។

រូបអាសអាភាសបំផ្លាញអ្នកប្រើប្រាស់វា ក៏ដូចជាជនរងគ្រោះរបស់វា។ វាបំពេញចំណង់ផ្លូវ

ចូរដើរក្នុងព្រះវិញ្ញាណ នោះអ្នករាល់គ្នានឹងមិនបំពេញ
សេចក្ដីប៉ងប្រាថ្នាខាងសាច់ឈាមទេ។ កាឡាទី ៥:១៦

ភេទ តាមរបៀបដែលមិនអាចនាំមកនូវការស្កប់ចិត្ត។ ការស្កប់ចិត្តពិតប្រាកដ គឺអាចរកឃើញ តែនៅពេលដែលយើងដើរតាមផ្លូវរបស់ព្រះ ហើយ "រកឃើញអ្វី ដែលព្រះអម្ចាស់សព្វព្រះទ័យ"។ ចូរយើងផ្តោតចិត្ត និងគំនិតជាទីមួយ ទៅលើទំនាក់ទំនងដ៏ត្រឹមត្រូវ ជាមួយព្រះវរបិតានៃយើង ដែលគង់នៅស្ថានសួគ៌។

## សូមអធិស្ឋានថា ...

ឱព្រះវរបិតា សូមជួយទូលបង្គំ ឲ្យរក្សាភ្នែកទូលបង្គំឲ្យបរិសុទ្ធ។ សូមជួយការពារទូលបង្គំ ឲ្យរួចផុតពីការល្បួង និងគ្រោះថ្នាក់នៃរូបអាសអាភាស។ ទូលបង្គំចង់ដើរតាមផ្លូវព្រះអង្គ ហើយចង់រស់នៅ ក្នុងជីវិត ដែលមានក្តីស្រឡាញ់ សេរីភាព និងសន្តិភាព។

ចូរដើរក្នុងព្រះវិញ្ញាណ នោះអ្នករាល់គ្នានឹងមិនបំពេញសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាមទេ។ កាឡាទី ៥:១៦

# កូឡុស ២:៩-១៧

៩ ដ្បិតមានគ្រប់ទាំងសេចក្ដីពោរពេញរបស់ព្រះ សណ្ឋិតនៅក្នុងទ្រង់ទាំងមានរូប
អង្គផង ១០ ហើយអ្នករាល់គ្នាក៏ពេញលេញក្នុងទ្រង់ ដែលទ្រង់ជាសិរសាលើអស់
ទាំងពួកគ្រប់គ្រង និងអំណាចទាំងប៉ុន្មាន ១១ អ្នករាល់គ្នាបានទទួលកាត់ស្បែក
ម្យ៉ាងក្នុងទ្រង់ ដែលមិនបានធ្វើដោយដៃមនុស្សទេ គឺជាការដោះរូបកាយខាង
សាច់ឈាមចេញ ដោយទទួលការកាត់ស្បែករបស់ព្រះគ្រីស្ទវិញ ១២ ហើយអ្នក
រាល់គ្នាបានកប់ជាមួយនឹងទ្រង់ក្នុងបុណ្យជ្រមុជ ក៏បានរស់ឡើងវិញជាមួយនឹង
ទ្រង់ ដោយសារសេចក្ដីជំនឿជឿដល់ឫទ្ធិបារមីនៃព្រះ ដែលទ្រង់បានប្រោសឲ្យ
ព្រះយេស៊ូវរស់ពីស្លាប់ឡើងវិញ ១៣ ឯអ្នករាល់គ្នាដែលបានស្លាប់ក្នុងការរំលង
ហើយក្នុងសណ្ឋានមិនកាត់ស្បែកខាងសាច់ឈាម នោះទ្រង់បានប្រោសឲ្យរស់ជា
មួយនឹងទ្រង់ ដោយបានអត់ទោសចំពោះអស់ទាំងការរំលងរបស់អ្នករាល់គ្នា ១៤
ទាំងលុបចោលសេចក្ដីដែលកត់ទុកទាស់នឹងយើងក្នុងសេចក្ដីបញ្ញត្ត ដែលប្រទាំង
នឹងយើង ហើយទ្រង់ក៏លើកចោល ដោយបោះភ្ជាប់នៅឈើឆ្កាង ១៥ ទ្រង់បាន
ទាំងទំលាក់ងារពីពួកគ្រប់គ្រង និងពួកមានអំណាច ទាំងដាក់ពួកទាំងនោះនៅ
កណ្ដាលជំនុំឲ្យគេមើល ហើយដឹកនាំគេទៅ ដោយមានជ័យជំនះ ដោយសារឈើ
ឆ្កាងនោះឯង។

១៦ ដូច្នេះ កុំទុកឲ្យអ្នកណានិន្ទាអ្នករាល់គ្នា ពីរឿងចំណីអាហារ ឬគ្រឿងផឹក ឬពី
រឿងថ្ងៃបុណ្យ ថ្ងៃចូលខែ ឬថ្ងៃឈប់សំរាកឡើយ ១៧ សេចក្ដីទាំងនេះជា
ស្រមោលនៃការដែលត្រូវមក តែតួរូបអង្គនោះ គឺជាព្រះគ្រីស្ទ។

# ដំដែកគោលភ្ជាប់នឹងឈើឆ្កាង

*ឯអ្នករាល់គ្នាដែលបានស្លាប់ក្នុងការរំលង ... នោះទ្រង់បានប្រោសឲ្យរស់ជាមួយនឹងទ្រង់ ដោយបានអត់ទោសចំពោះអស់ទាំងការរំលងរបស់អ្នករាល់គ្នា(កូល៉ុស ២:១៣)។*

មានពេលមួយយើងមានការជួបជុំដ៏មានអំណាច ក្នុងពួកជំនុំ។ គ្រូគង្វាលបានចែកចាយ អំពីការដែលព្រះយេស៊ូវផ្ទុកបាបរបស់យើង នៅលើអង្គទ្រង់ និងសុគតជំនួសយើង ដើម្បីទទួលទោសនៃអំពើបាបរបស់យើង។ គាត់ក៏បានសួរថា ក្នុងចំណោមយើង តើមាននរណានៅមានអារម្មណ៍ ប្រកាន់ទោសខ្លួនឯង ដោយសារការអ្វីដែលពួកគេបានធ្វើខុសកាលពីអតីតកាល ឬដោយសារការអ្វីដែលពួកគេពិបាកជំរុះចោល ហើយតើយើងមានអារម្មណ៍ថា មានអ្វីរាំងមិនឲ្យយើងអរសប្បាយ ចំពោះការអត់ទោសបាបរបស់ព្រះឬទេ។

គាត់ក៏បានប្រាប់យើងឲ្យសរសេរ អំពីអំពើបាប ការញៀន ឬការអ្វីក៏ដោយ នៅលើក្រដាស់មួយសន្លឹក ហើយដើរទៅខាងមុខព្រះវិហារ ហើយយកដែកគោលដំភ្ជាប់ក្រដាស់នោះនៅលើឈើឆ្កាង ដែលគេបានដាក់នៅទីនោះ។ គ្នាយើងជាច្រើននាក់ក៏បានដើរទៅមុខ ហើយយើងអាចឮសម្លេងគេដំដែកគោល អស់បីបួននាទី។ ជាការពិតណាស់ ការធ្វើដូចនេះ មិនបានផ្តល់ឲ្យយើងនូវការអត់ទោសបាបទេ ប៉ុន្តែវាបានរំឭកយើងថា ព្រះយេស៊ូវបានទទួលយកអំពើបាបរបស់យើង ផ្ទុកនៅលើអង្គទ្រង់ កាលព្រះអង្គកំពុងជាប់នៅលើឈើឆ្កាង រហូតដល់អស់ព្រះជន្ម។

ពួកជំនុំនៅក្រុងកូល៉ុស ត្រូវបានពួកគ្រូខុសឆ្គងនាំឲ្យវង្វេង ដោយបង្រៀនពួកគេថា ព្រះយេស៊ូវមិនមានភាពគ្រប់គ្រាន់ ដើម្បីឲ្យពួកគេផ្លាស់ប្រែជាថ្មីជាមួយព្រះនោះឡើយ។ ប៉ុន្តែ សាវ័កប៉ុលក៏បានពន្យល់ថា ព្រះយេស៊ូវបានបង់ថ្លៃលោះបាបយើងមួយរយភាគរយហើយ។ គាត់ថា ព្រះយេស៊ូវបាន "ទាំងលុបចោលសេចក្តីដែលកត់ទុកទាស់នឹងយើងក្នុងសេចក្តីបញ្ញត្ត ដែលប្រទាំងនឹងយើង ហើយទ្រង់ក៏លើកចោល ដោយបោះភ្ជាប់នៅឈើឆ្កាង"(កូល៉ុស ២:១៤)។

**ដ្បិតឯព្រះអង្គ ដែលមិនបានស្គាល់បាបសោះ នោះទ្រង់បានធ្វើឲ្យត្រឡប់ជាតួបាបជំនួសយើងរាល់គ្នាវិញ ដើម្បីឲ្យយើងរាល់គ្នាបានត្រឡប់ទៅជាសេចក្តីសុចរិតរបស់ព្រះ ដោយនូវព្រះអង្គនោះឯង។ ២កូរិនថូស ៥:២១**

ការតយុទ្ធនឹងការញៀន ដែលរាប់បញ្ចូលទាំងការញៀនរូបអាសអាភាស អាចធ្វើឲ្យយើងមានអារម្មណ៍ថា យើងបានងាកបែរចេញពីព្រះឆ្ងាយពេក ព្រះអង្គមិនអាចសង្គ្រោះយើងបានទេ។ ប៉ុន្តែ នេះមិនមែនជាព្រះរាជសារពិត របស់ការសុគតរបស់ព្រះយេស៊ូវ នៅលើឈើឆ្កាងនោះឡើយ។ ព្រះអង្គមិនបានយាងមក ដើម្បីលោះបាបជាច្រើននោះទេ តែព្រះអង្គបាន "អត់ទោសឲ្យអំពើបាបទាំងអស់របស់យើង"(កូល៉ុស ២:១៣)។ បើយើងទទួលស្គាល់ថា យើងបានធ្វើខុសនឹងព្រះ ហើយទូលសូមឲ្យព្រះអង្គអត់ទោសឲ្យ ព្រះអង្គនឹងអត់ទោសឲ្យយើង(១យ៉ូហាន ១:៩)។ យើងមិនចាំបាច់ត្រូវបន្តរស់នៅក្នុងអំពើបាប និងភាពអាម៉ាសទៀតឡើយ ព្រោះព្រះអង្គបានទទួលពីយើងអស់ហើយ។ អំពើបាបនីមួយៗរបស់យើង ត្រូវបានបោះភ្ជាប់ឈើឆ្កាង ពោលគឺព្រះអង្គបានយកចេញពីយើងហើយ។ ព្រះយេស៊ូវបានអត់ទោសឲ្យអំពើបាបទាំងអស់របស់យើង។

## តើខ្ញុំត្រូវអរព្រះគុណព្រះអង្គ សម្រាប់ការអ្វីខ្លះ?

ឱព្រះយេស៊ូវ ទូលបង្គំមានការស្ងប់ស្ងែង ចំពោះព្រះអង្គ ដ្បិតព្រះអង្គបានសុគតជំនួសទូលបង្គំ ដើម្បីបង់ថ្លៃលោះ សម្រាប់កំហុស និងអំពើបាបនីមួយៗរបស់ទូលបង្គំ ដោយរាប់បញ្ចូលទាំងការញៀនរូបអាសអាភាសផងដែរ។
ទូលបង្គំសូមអរព្រះគុណព្រះអង្គ។

**ដ្បិតឯព្រះអង្គ ដែលមិនបានស្គាល់បាបសោះ នោះទ្រង់បានធ្វើឲ្យត្រឡប់ជាតួបាបជំនួសយើងរាល់គ្នាវិញ ដើម្បីឲ្យយើងរាល់គ្នាបានត្រឡប់ទៅជាសេចក្ដីសុចរិតរបស់ព្រះ ដោយនូវព្រះអង្គនោះឯង។ ២កូរិនថូស ៥:២១**

# រ៉ូម ៨:១-១៧

១ ហេតុនោះ នៅជាន់នេះ អ្នកណាដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ នោះគ្មានទោសសោះ ២
ដ្បិតអំណាចរបស់ព្រះវិញ្ញាណនៃជីវិត ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ នោះបានប្រោសឲ្យខ្ញុំរួច
ពីអំណាចរបស់អំពើបាប និងសេចក្តីស្លាប់ហើយ ៣ ពីព្រោះ ឯការដែលក្រឹត្យវិន័យធ្វើមិនកើត
ដោយមានសេចក្តីកំសោយព្រោះសាច់ឈាម នោះព្រះទ្រង់បានធ្វើវិញ ដោយចាត់ព្រះរាជ
បុត្រាទ្រង់ឲ្យមក មានរូបអង្គបែបដូចជាសាច់ឈាម ដែលតែងតែមានបាប ហើយដោយព្រោះ
អំពើបាប ក៏កាត់ទោសអំពើបាបនៅក្នុងសាច់ឈាម ៤ ដើម្បីឲ្យសេចក្តីក្រឹត្យវិន័យបង្គាប់មក
បានសំរេចក្នុងខ្លួនយើងរាល់គ្នា ដែលមិនដើរតាមសាច់ឈាម គឺដើរតាមព្រះវិញ្ញាណវិញ ៥ ពី
ព្រោះអស់អ្នកណាដែលតាមសាច់ឈាម នោះគិតតែខាងសាច់ឈាម តែអស់អ្នកណាដែល
គិតតាមព្រះវិញ្ញាណ នោះគិតតែខាងវិញ្ញាណវិញ ៦ ដ្បិតគំនិតខាងសាច់ឈាម នោះជាសេច
ក្តីស្លាប់ទទេ ឯគំនិតនៃព្រះវិញ្ញាណ នោះទើបជាជីវិត និងសេចក្តីសុខសាន្តវិញ ៧ ព្រោះគំនិត
ខាងសាច់ឈាម នោះរមែងទាស់ទទឹងនឹងព្រះ ដ្បិតមិនចុះចូលនឹងក្រឹត្យវិន័យរបស់ព្រះទេ ក៏
ពុំអាចនឹងចុះចូលបានផង ៨ ពួកអ្នកដែលនៅខាងសាច់ឈាម នោះពុំអាចនឹងគាប់ព្រះ
ហឫទ័យដល់ព្រះបានឡើយ ៩ តែបើសិនជាព្រះវិញ្ញាណនៃព្រះសណ្ឋិតក្នុងអ្នករាល់គ្នា នោះ
អ្នករាល់គ្នាមិននៅខាងសាច់ឈាមទៀតទេ គឺនៅខាងវិញ្ញាណវិញ ប៉ុន្តែ បើអ្នកណាគ្មានព្រះ
វិញ្ញាណរបស់ព្រះគ្រីស្ទ អ្នកនោះមិនមែនជារបស់ផងទ្រង់ទេ ១០ ហើយបើសិនជាព្រះគ្រីស្ទ
សណ្ឋិតក្នុងអ្នករាល់គ្នា នោះរូបសាច់បានស្លាប់ ដោយព្រោះអំពើបាបមែន តែវិញ្ញាណមាន
ជីវិតវិញ ដោយព្រោះសេចក្តីសុចរិត ១១ មួយទៀត បើព្រះវិញ្ញាណនៃព្រះអង្គ ដែលបាន
ប្រោសឲ្យព្រះយេស៊ូវរស់ពីស្លាប់ឡើងវិញ ទ្រង់សណ្ឋិតក្នុងខ្លួនអ្នករាល់គ្នា នោះព្រះអង្គនោះ
ឯង ដែលបានប្រោសឲ្យព្រះគ្រីស្ទរស់ពីស្លាប់ឡើង ទ្រង់នឹងប្រោសរូបកាយនៃអ្នករាល់គ្នា
ដែលទៀងតែស្លាប់ ឲ្យមានជីវិតឡើងដែរ ដោយសារព្រះវិញ្ញាណទ្រង់ ដែលសណ្ឋិតនៅក្នុង
ខ្លួនអ្នករាល់គ្នា។

១២ ដូច្នេះ បងប្អូនអើយ យើងមានសេចក្តីជាប់ជំពាក់ មិនមែនជំពាក់ចំពោះសាច់ឈាម ឲ្យ
បានរស់តាមសាច់ឈាមនោះទេ ១៣ ដ្បិតបើសិនជាអ្នករាល់គ្នារស់តាមសាច់ឈាម នោះនឹង
ត្រូវស្លាប់ទៅ តែបើសំឡាប់អំពើរបស់រូបសាច់ចេញ ដោយសារព្រះវិញ្ញាណ នោះអ្នករាល់គ្នា
នឹងបានរស់វិញ ១៤ ហើយអស់អ្នកណាដែលព្រះវិញ្ញាណនៃព្រះទ្រង់នាំ អ្នកទាំងនោះហើយ
ជាពួកកូនរបស់ព្រះ ១៥ អ្នករាល់គ្នាមិនបានទទួលនិស្ស័យជាបាវបំរើ ឲ្យត្រូវភ័យខ្លាចទៀត
ឡើយ គឺបានទទួលនិស្ស័យជាកូនចិញ្ចឹមវិញ ដោយហេតុនោះបានជាយើងស្រែកឡើងថា ឱ
អ័ប្បា ព្រះវរបិតាអើយ ១៦ ហើយព្រះវិញ្ញាណទ្រង់ក៏ធ្វើបន្ទាល់នឹងវិញ្ញាណយើងថា យើងជា
កូនរបស់ព្រះ ១៧ បើសិនណាជាកូនព្រះហើយ នោះយើងក៏បានគ្រងមរដកដែរ គឺជាអ្នកគ្រង
មរដកនៃព្រះជាមួយនឹងព្រះគ្រីស្ទផង ឲ្យតែយើងទទួលរងទុក្ខជាមួយនឹងទ្រង់ចុះ ដើម្បីឲ្យ
បានដំកើងឡើងជាមួយនឹងទ្រង់ដែរ។

# ការផ្លាស់ប្តូរ

ហេតុនោះ នៅជាន់នេះ អ្នកណាដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ
នោះគ្មានទោសសោះ(រ៉ូម ៨:១)។

កាលខ្ញុំនៅក្មេង សត្វមាន់ក្នុងភូមិខ្ញុំ មានចំណុចដែលធ្វើឲ្យខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំង។ ពេលណាខ្ញុំចាប់បានមាន់មួយក្បាល ខ្ញុំក៏បានសង្កត់វាកុំឲ្យរើមួយសន្ទុះ រួចខ្ញុំក៏ព្រលែងវាយឺតៗ។ ពេលនោះសត្វមាន់នៅតែបន្តដេកនៅលើដីទៀត ដោយគិតថា ខ្ញុំកំពុងតែចាប់វា។ វាអាចរត់ដោយសេរី ព្រោះខ្ញុំបានលែងវាហើយ តែវានៅតែគិតថា ខ្លួនវានៅបន្តជាប់ចំណង។

ពេលណាយើងទទួលជឿព្រះយេស៊ូវ ព្រះអង្គក៏រំដោះយើងឲ្យរួចពីអំពើបាប និងចំណងអំពើបាប និងវិញ្ញាណអាក្រក់ ដែលបានចងវិញ្ញាណយើងជាប់។ ប៉ុន្តែ ការផ្លាស់ប្តូរទម្លាប់ និងរបៀបនៃការរស់នៅ ត្រូវចំណាយពេល ដូចនេះ ជួនកាល យើងនៅតែបន្តមានអារម្មណ៍ថា យើងនៅជាប់ចំណង។ ប៉ុន្តែ ព្រះទ្រង់បានរំដោះយើងឲ្យមានសេរីភាព ដោយព្រះវិញ្ញាណព្រះអង្គគង់នៅក្នុងយើង។

សាវ័កប៉ុលបានប្រាប់ពួកជំនុំនៅទីក្រុងរ៉ូមថា "ហេតុនោះ នៅជាន់នេះ អ្នកណាដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ នោះគ្មានទោសសោះ ដ្បិតអំណាចរបស់ព្រះវិញ្ញាណនៃជីវិត ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ នោះបានប្រោសឲ្យខ្ញុំរួចពីអំណាចរបស់អំពើបាប និងសេចក្តីស្លាប់ហើយ"(រ៉ូម ៨:១-២)។

តាមរយៈការអានព្រះគម្ពីរប៊ីប ការអធិស្ឋាន និងអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ ព្រះទ្រង់ធ្វើការក្នុងយើង ដើម្បីកែប្រែ និងជួយយើងឲ្យរស់នៅថ្វាយព្រះអង្គ។ ព្រះគម្ពីរបានប្រាប់យើងថា យើងអាចមានទំនុកចិត្ត នៅក្នុងការដើរជាមួយព្រះយេស៊ូវ។ គ្មានអ្វីអាចពង្រាត់យើងចេញពីព្រះអង្គបានឡើយ(ខ.៣៨-៣៩)។

ព្រះយេស៊ូវមានបន្ទូលថា "បើព្រះរាជបុត្រាប្រោសឲ្យអ្នករាល់គ្នាបានរួច នោះនឹងបានរួចជាពិត"(យ៉ូហាន ៨:៣៦)។ សូមឲ្យសេរីភាពដែលយើងមានក្នុងព្រះយេស៊ូវ បានផ្តល់ឲ្យយើងនូវកម្លាំង ដើម្បីស្រឡាញ់ និងបម្រើព្រះអង្គ។

## ការអធិស្ឋាន :

ឱព្រះយេស៊ូវ សូមអរព្រះគុណព្រះអង្គ សម្រាប់ការប្រទានសេរីភាព ក្នុងការដើរតាមព្រះអង្គ។
នៅថ្ងៃខ្លះ ទូលបង្គំមានអារម្មណ៍ថា ពិបាកពេក នៅក្នុងការតយុទ្ធនឹងការញៀនរូបអាសអាភាស។
សូមព្រះអង្គជួយទូលបង្គំឲ្យបន្តផ្តោតទៅលើព្រះអង្គ ហើយបន្តជញ្ជឹងគិត អំពីព្រះជន្ម ការសុគត
និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ។

**ខ្ញុំជឿសេចក្តីនេះជាយ៉ាងជាក់ថា ព្រះអង្គដែលទ្រង់បានចាប់តាំងធ្វើការល្អក្នុងអ្នករាល់គ្នា ទ្រង់នឹងធ្វើឲ្យកាន់តែពេញខ្នាតឡើង ទាល់តែដល់ថ្ងៃនៃព្រះយេស៊ូវគ្រីស្ទ។ ភីលីព ១:៦**

# រ៉ូម ៦:១៣-២៣

១៣ ក៏កុំឲ្យប្រគល់អវយវៈទាំងប៉ុន្មាន របស់អ្នករាល់គ្នាទៅក្នុងអំពើបាប ទុកដូចជាប្រដាប់
ទុច្ចរិតនោះឡើយ គឺត្រូវប្រគល់ខ្លួនទៅព្រះ ដូចជាបានរស់ពីស្លាប់នោះឡើងវិញ ហើយថ្វាយអ
វយវៈរបស់អ្នករាល់គ្នាទៅព្រះ ទុកដូចជាប្រដាប់ប្រដាសុចរិតផង ១៤ ដ្បិតបាបមិនត្រូវមាន
អំណាចលើអ្នករាល់គ្នាទៀតឡើយ ដោយព្រោះអ្នករាល់គ្នាមិននៅក្រោមក្រឹត្យវិន័យ គឺនៅ
ក្រោមព្រះគុណវិញ។ ១៥ ដូច្នេះ ធ្វើដូចម្តេច តើគួរឲ្យយើងប្រព្រឹត្តអំពើបាប ដោយព្រោះនៅ
ក្រោមព្រះគុណ មិននៅក្រោមក្រឹត្យវិន័យឬអី ទេ មិនគួរឡើយ ១៦ តើអ្នករាល់គ្នាដឹងទេឬអី
ថាអ្នករាល់គ្នាប្រគល់ខ្លួនទៅធ្វើជាបាវបំរើ និងស្តាប់តាមចៅហ្វាយណា នោះអ្នកជាបាវបំរើ
របស់ចៅហ្វាយនោះឯងដែលអ្នកស្តាប់តាម ទោះជារបស់ផងអំពើបាប ឲ្យបានសេចក្តីស្លាប់ ឬ
ជារបស់ផងសេចក្តីស្តាប់បង្គាប់ ឲ្យបានសុចរិតក្តី ១៧ ឯអ្នករាល់គ្នា ពីដើមជាបាវបំរើរបស់
អំពើបាបមែន ប៉ុន្តែអរព្រះគុណដល់ព្រះអង្គ ឥឡូវនេះ បានស្តាប់ដោយស្ម័គ្រពីចិត្ត តាមក្បួន
នៃលទ្ធិ ដែលគេបានប្រគល់មកអ្នករាល់គ្នា ១៨ ហើយអ្នករាល់គ្នាបានត្រឡប់ជាបាវបំរើនៃ
សេចក្តីសុចរិតវិញ ដោយទ្រង់បានប្រោសឲ្យរួចពីអំពើបាបហើយ ១៩ ខ្ញុំនិយាយតាមបែប
មនុស្សលោក ដោយព្រោះសេចក្តីកំសោយរបស់សាច់ឈាមនៃអ្នករាល់គ្នា ដ្បិតដូចជាកាលពី
ដើម អ្នករាល់គ្នាបានប្រគល់អវយវៈទាំងប៉ុន្មាន ទៅបំរើសេចក្តីស្មោកគ្រោក និងសេចក្តីទទឹង
ច្បាប់ កាន់តែច្រើនឡើងយ៉ាងណា ឥឡូវនេះ ចូរអ្នករាល់គ្នាប្រគល់អវយវៈទាំងអស់នោះ ទៅ
បំរើសេចក្តីសុចរិតវិញ ប្រយោជន៍ឲ្យបានបរិសុទ្ធយ៉ាងនោះដែរ ២០ ពីព្រោះកាលពីដើម ដែល
នៅជាបាវបំរើរបស់អំពើបាប នោះអ្នករាល់គ្នាមិននៅក្នុងអំណាចនៃសេចក្តីសុចរិតទេ ២១
កាលណោះតើអ្នករាល់គ្នាបានផលអ្វីខ្លះ ក្នុងអំពើដែលឥឡូវនេះអ្នករាល់គ្នាអៀនខ្មាសវិញ
ដ្បិតទីបំផុតនៃអំពើទាំងនោះជាសេចក្តីស្លាប់ ២២ តែឥឡូវនេះ ដែលព្រះបានប្រោសឲ្យរួចពី
បាប ហើយអ្នករាល់គ្នាបានត្រឡប់ជាបាវបំរើដល់ទ្រង់ នោះអ្នករាល់គ្នាបានផលខាងឯសេចក្តី
បរិសុទ្ធវិញ ហើយទីបំផុតនៃអំពើទាំងនោះ គឺជាជីវិតអស់កល្បជានិច្ចផង ២៣ ដ្បិតឈ្នួល
របស់អំពើបាប នោះជាសេចក្តីស្លាប់ តែអំណោយទាននៃព្រះវិញ គឺជាជីវិតដ៏នៅអស់កល្បជា
និច្ច ដោយព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នា។

# សេរីភាព

កុំឲ្យប្រគល់អវយវៈទាំងប៉ុន្មាន របស់អ្នករាល់គ្នាទៅក្នុងអំពើបាប ទុកដូចជាប្រដាប់ទុច្ចរិតនោះឡើយ គឺត្រូវប្រគល់ខ្លួនទៅព្រះ ដូចជាបានរស់ពីស្លាប់នោះឡើងវិញ ហើយថ្វាយអវយវៈរបស់អ្នករាល់គ្នាទៅព្រះ ទុកដូចជាប្រដាប់ប្រដាសុចរិតផង។ រ៉ូម ៦:១៣

មិត្តភក្តិរបស់បេត(Beth) ដែលជាគ្រីស្ទបរិសុទ្ធ ក្នុងក្រុមយុវជន សុទ្ធតែនិយាយអំពីរឿងភាគមួយ ដែលពួកគេបានចាក់បញ្ចាំងនៅលើកញ្ចក់ទូរទស្សន៍។ ដូចនេះ បេតក៏បានសម្រេចចិត្តមើលរឿងនោះដែរ។ បន្ទាប់ពីនាងបានមើលបានពីរភាគ នាងក៏មានការភ្ញាក់ផ្អើល ចំពោះឈុតឆាកផ្លូវភេទច្បាស់ៗ។ នាងក៏បានឈប់មើលរឿងនោះទៀត តែនាងមិនយល់សោះថា ហេតុអ្វីពួកគេនៅតែបន្តមើលវាទៀត។

ក្នុងនាមយើងជាគ្រីស្ទបរិស័ទ ព្រះគម្ពីរបានប្រាប់យើងថា “ព្រះគ្រីស្ទបានរំដោះយើងឲ្យមានសេរីភាពហើយ”(កាឡាទី ៥:១)។ ប៉ុន្តែ តើយើងនឹងប្រើសេរីភាពនោះ ដោយរបៀបណា ជាពិសេស ខណៈពេលដែលយើងរស់នៅ ថ្វាយព្រះដ៏ឥតខ្ចោះ និងបរិសុទ្ធ ដែលសព្វព្រះទ័យឲ្យយើងមានលក្ខណៈល្អដូចព្រះអង្គ? តើការដែលយើងមានសេរីភាពក្នុងព្រះយេស៊ូវ មានន័យថា យើងចង់មើលអ្វីក៏បាននៅលើកញ្ចប់ទូរទស្សន៍ ឬនៅលើបណ្តាញអ៊ីនធើណិតឬ? តើខ្សែភាពយន្ត ដែលមានឈុតឆាកស្រើបស្រាល ឬអាក្រាតកាយជារឿងធម្មតា ដែលយើងគ្រាន់តែញាក់ស្មា ហើយមើលវាឬ?

សាវ័កប៉ុលបានផ្តល់ឲ្យយើងនូវការណែនាំក្នុងព្រះគម្ពីរប៊ីប ដែលនៅតែមានភាពចាំបាច់សម្រាប់ពេលបច្ចុប្បន្ន។ គាត់បានរំឭកយើងថា យើងបានក្លាយជាគ្រីស្ទបរិស័ទ គឺដោយសារសេចក្តីស្រឡាញ់ និងព្រះគុណព្រះអង្គ។ តែគាត់ក៏មានប្រសាសន៍ផងដែរថា ព្រះបានប្រទានព្រះគុណមក មិនមែនដើម្បីឲ្យយើងអាចធ្វើអ្វីតាមចិត្ត ដោយគិតថា ព្រះអង្គនឹងអត់ទោសឲ្យយើងនោះឡើយ(រ៉ូម ៦:១-២)។

ជីវិតរបស់យើង មិនជាប់ជាទាសករ នៃអំពើបាប និងសេចក្តីស្លាប់ទៀតទេ

**គឺត្រូវចុះចូលទុកដូចជាមនុស្សមានសេរីភាព តែមិនមែនដោយប្រើសេរីនោះ ដើម្បីនឹងបំបិតបំបាំងសេចក្តីអាក្រក់ឡើយ ត្រូវចុះចូលដូចជាអ្នកបំរើរបស់ព្រះវិញ។ ១ពេត្រុស ២:១៦**

(ខ.២២) តែយើងត្រូវប្រើសេរីភាពរបស់យើង ដើម្បីនាំលោកិយ ឲ្យស្គាល់ព្រះយេស៊ូវ ក្នុងស្ថានភាព និងកាលៈទេសៈនីមួយៗ(ដោយរាប់បញ្ចូលទាំងខ្សែវីដេអូដែលយើងសម្រេចចិត្តមើល ជាមួយមិត្តភក្តិរបស់យើងផងដែរ)។ ជាការពិតណាស់ យើងមានសេរីភាព នៅក្នុងការទស្សនាវីដេអូ ទៅកន្លែងណា និងធ្វើអ្វីដែលយើងសម្រេចចិត្តធ្វើ ដោយប្រើពេលវេលារបស់យើង ... តែយើងត្រូវធ្វើការទាំងអស់នេះ ដើម្បីផ្គាប់ចិត្តព្រះ ហើយបង្ហាញឲ្យគេដឹងថា ព្រះអង្គកំពុងតែធ្វើការយ៉ាងសកម្ម ក្នុងជីវិតយើង។

នៅក្នុងការទាំងអស់ ដែលយើងធ្វើ បើយើងមិនថ្វាយខ្លួនយើងដល់ព្រះទេ នោះមានន័យថា យើងប្រគល់ខ្លួនយើងឲ្យទៅអំពើបាបហើយ។ ដូចនេះ ចូរយើង "រាប់ខ្លួនទុកជាស្លាប់ខាងបាបដែរ តែរស់ខាងឯព្រះវិញចុះ"(ខ.១១)។

## តើមានអ្វីទៀត ?

*សូមអានបទគម្ពីរ កាឡាទី ៥:១៦-២៦ ដើម្បីស្វែងយល់ អំពីរបៀប និងលក្ខណៈនៃការរស់នៅ ក្នុងសេរីភាព។*

**គឺត្រូវចុះចូលទុកដូចជាមនុស្សមានសេរីភាព តែមិនមែនដោយប្រើសេរីនោះ ដើម្បីនឹងបំបិតបំបាំងសេចក្តីអាក្រក់ឡើយ ត្រូវចុះចូលដូចជាអ្នកបំរើរបស់ព្រះវិញ។**
**១ពេត្រុស ២:១៦**



# តើខ្ញុំញៀនហើយឬ?

រូបអាសអាភាស ត្រូវបានគេបង្កើតមក ដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់អ្នក។ មនុស្សជាច្រើនត្រូវបានមិត្តភក្តិនាំឲ្យមើលរូបអាសអាភាស ហើយអ្នកខ្លះ ថែមទាំងរកឃើញរូបអាសអាភាសដោយខ្លួនឯងនៅផ្ទះ។ រូបអាសអាភាសប្រហែលជា ធ្វើឲ្យអ្នកមានអារម្មណ៍រំភើប ប៉ុន្តែ តើអ្នកអាចគ្រប់គ្រងអារម្មណ៍ខ្លួនឯងបានទេ? រូបអាសអាភាសធ្វើឲ្យយើងជាប់ចិត្តនឹងវា វាទាញយើងចូលកាន់តែជ្រៅ ហើយគ្រប់គ្រងមកលើយើង ទាល់តែយើងស្ទើរតែមិនអាចមានចំណាប់អារម្មណ៍មកលើអ្វីផ្សេងទៀត។

តើអ្នកញៀននឹងរូបអាសអាភាសឬ? តើអ្នកកំពុងតែធ្វើនូវចំណុចខាងក្រោមនេះទេ?

- ខ្ញុំបានស្វែងរកមើលរូបអាសអាភាសជាទៀងទាត់
- ជាញឹកញាប់ ខ្ញុំបានចំណាយពេលមួយផ្នែក ក្នុងថ្ងៃនីមួយៗ ដើម្បីគិត និងរង់ចាំពេលដែលខ្ញុំអាចមើលរូបអាសអាភាស
- អារម្មណ៍របស់ខ្ញុំមានការផ្លាស់ប្តូរឥតឈប់ ពិបាកគ្រប់គ្រង់អារម្មណ៍ និងចំណង់ខ្លួនឯង។
- ខ្ញុំមិនអាចប្រាប់នរណាម្នាក់ អំពីអាថ៌កំបាំងរបស់ខ្ញុំបានទេ
- ខ្ញុំនិយាយកុហក់ ដើម្បីលាក់បាំងបញ្ហារបស់ខ្ញុំ

## តើខ្ញុំអាចផ្តាច់ការញៀន ដោយរបៀបណា?

ក្រុមស្តានិតិសម្បទាអ្នកប្រមឹកស្រាអនាមិក(ក្រុមដែលជួយអ្នកញៀនស្រា ឬជួយផ្តាច់ការញៀនស្រា) មានកម្មវិធី១២ជំហាន ដើម្បីជួយអ្នកញៀនស្រារកឃើញសេរីភាព។ បើអ្នកញៀននឹងរូបអាសអាភាស ខាងក្រោមនេះ ជាវិធីសាស្ត្រ ដែលមាន១២ជំហាន ដែលស្រដៀងនឹងវិធីសាស្រផ្តាច់ការញៀនស្រា ដែលអ្នកអាចអនុវត្តតាម ដោយជោគជ័យ :

1. ចូរទទួលស្គាល់ថា អ្នកគ្មានអំណាចអ្វី ដើម្បីឈ្នះការញៀនរបស់អ្នក ហើយមិនអាចគ្រប់គ្រងវាបានឡើយ(អេភេសូរ ២:១-៧)។
2. ចូរជឿថា មានតែអំណាច និងកម្លាំងរបស់ព្រះទេ ដែលអាចរំដោះអ្នក ហើយស្អាងអ្នកឡើងវិញ(អេភេសូរ ២:៨-៩)។
3. ចូរធ្វើការសម្រេចចិត្តថា អ្នកនឹងថ្វាយចិត្ត និងជីវិតអ្នក ដាច់ដល់ព្រះ(រ៉ូម ១០:៩)។
4. ចូរឆែកពិនិត្យមើលជីវិតរបស់អ្នក ដោយចិត្តស្មោះត្រង់ ដោយមិនលាក់បាំង ឬដោះសារ ចំពោះអ្វីដែលអ្នករកឃើញនោះឡើយ(១យ៉ូហាន ១:៨-១០)។
5. ចូរទូលថ្វាយព្រះ និងនិយាយប្រាប់ខ្លួនឯង និងមនុស្សម្នាក់(ប្រហែលអ្នកដឹកនាំយុវជនរបស់អ្នក) អំពីធាតុពិតនៃការញៀនរបស់អ្នក។ ចូរសូមឲ្យគាត់អធិស្ឋានឲ្យ លើកទឹកចិត្ត និងជួយឲ្យអ្នកកែប្រែ ដោយការទទួលខុសត្រូវ(កាឡាទី ៦:១-៣)។
6. ចូរបន្ទាបខ្លួន ទូលសូមព្រះ ឲ្យដកចំណុចខ្សោយរបស់អ្នកចេញ(រ៉ូម ១២:១-២)។
7. ចូរស្ម័គ្រចិត្ត និងត្រៀមខ្លួន ដើម្បីឲ្យព្រះកែប្រែជីវិត និងកែប្រែចរិកលក្ខណៈរបស់អ្នក ដើម្បីឲ្យអ្នកអាចរស់នៅ ដោយបើកចំហរ មិនមែនដោយអាថ៌កំបាំង ហើយនាំឲ្យគេឃើញព្រះអង្គ ធ្វើការកែប្រែជីវិតអ្នក ដោយគ្មានក្តីអាម៉ាស់(យ៉ូហាន ៣:១៩-២០)។

8. ចូររាយឈ្មោះមនុស្សទាំងអស់ ដែលទទួលរងការឈឺចាប់ ដោយសារការញៀនរបស់អ្នក ហើយចូរស្ម័គ្រចិត្ត ទៅសុំទោសពួកគេ ហើយធ្វើការកែប្រែ (ភីលីព ២:៣)។
9. ចូរធ្វើការផ្សះផ្សាជាមួយពួកគេ តាមដែលអាចធ្វើទៅបាន(រ៉ូម ១២:១៨)។
10. ចូរបន្តពិនិត្យមើលខ្លួនឯង ដោយចិត្តស្មោះត្រង់ ហើយឆាប់ទូលថ្វាយព្រះ និងនិយាយប្រាប់នរណាម្នាក់(ដែលអ្នករួមដំណើរជីវិតជាមួយ) អំពីអ្វីដែលអ្នកបានធ្វើខុស(រ៉ូម ២:១-៦)។
11. ចូរបន្តអធិស្ឋាន អានព្រះគម្ពីរប៊ីប ហើយជញ្ជឹងគិត អំពីអ្វីដែលមានចែងក្នុងព្រះគម្ពីរ ដោយមានចិត្តរំពឹងចង់ចូលទៅជិតព្រះជានិច្ច។ ចូរទូលសូមកម្លាំងពីព្រះវិញ្ញាណព្រះអង្គ ដើម្បីបន្តរស់នៅក្នុងជីវិត ដែលបរិសុទ្ធ និងមានសន្តិភាព(ហេព្រើរ ៤:១២-១៦)។
12. ចូរស្វែងរក និងរំពឹងចង់បានការផ្លាស់ប្តូរ ក្នុងជីវិតអ្នក តាមជំហានទាំងនេះ។
13. ចូរអនុវត្តតាមជំហាននីមួយៗ យ៉ាងសកម្ម ជំហានទាំងនេះមិនកើតមាន ក្នុងជីវិតអ្នក ដោយខ្លួនឯងនោះឡើយ(កាឡាទី ៥:១៦-២៦)។

បទគម្ពីរជាភាសាខ្មែរដកស្រង់ចេញពីព្រះគម្ពីរបរិសុទ្ធ ភាសាខ្មែរ បកប្រែចាស់ ឆ្នាំ១៩៥៤ ដោយការ
អនុញ្ញាតិ និងរក្សាសិទ្ធិដោយសមាគមន៍ព្រះគម្ពីរសកល (បានដកស្រង់ ដោយរក្សាអក្ខរាវិរុទ្ធដើម)។
រក្សាសិទ្ធិគ្រប់យ៉ាងដោយ: © 2020 ODB Ministries ( website: www.khmer-odb.org )

នំម៉ាណាប្រចាំថ្ងៃ
www.khmer-odb.org